ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខៈ.........០០២/១៦......គ.ម.ក/ប្រ.ក.

# ប្រកាស

## ស្តីពី

## វិសោធនកម្មប្រការ ២ នៃប្រកាសលេខ ០០១/១២ គ.ម.ក./ប្រ.ក

## ស្តីពី

## ការកំណត់កម្រៃសេវាសម្រាប់ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន នៅក្នុងវិស័យមូលបត្រ

*****

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- បានឃើញប្រកាសលេខ ០០១ គ.ម.ក. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- បានឃើញប្រកាសលេខ ០០៨ គ.ម.ក.ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ
- បានឃើញប្រកាសលេខ ០០១/១២ គ.ម.ក./ប្រ.ក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការកំណត់កម្រៃសេវាសម្រាប់ការផ្តល់លេខអត្តសញ្ញាណវិនិយោគិននៅក្នុងវិស័យមូលបត្រ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤

## ស ម្រេ ច

**ប្រការមួយ.-**

ត្រូវបានកែសម្រួលប្រការ ២ នៃប្រកាសលេខ ០០១/១២ គ.ម.ក./ប្រ.ក ស្តីពីការកំណត់កម្រៃសេវាសម្រាប់ការផ្តល់លេខអត្តសញ្ញាណវិនិយោគិននៅក្នុងវិស័យមូលបត្រ ដែលមានខ្លឹមសារដូចខាងក្រោម÷

ប្រការ ២ថ្មីៈ បុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត នៅពេលដាក់ពាក្យស្នើសុំ ឬស្នើសុំបន្តលេខអត្តសញ្ញាណវិនិយោគិន នៅ គ.ម.ក ទៅតាមចំនួនដូចខាងក្រោម÷

- ជាសាច់ប្រាក់ចំនួន ២០.០០០(ពីរម៉ឺន) រៀល ចំពោះរូបវន្តបុគ្គល។
- ជាសាច់ប្រាក់ចំនួន ៥០.០០០(ប្រាំម៉ឺន) រៀល ចំពោះនីតិបុគ្គល។

លេខអត្តសញ្ញាណវិនិយោគិន មានសុពលភាពសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ។ វិនិយោគិនត្រូវដាក់ពាក្យស្នើសុំបន្តលេខអត្តសញ្ញាណវិនិយោគិន មុនពេលអស់សុពលភាពរយៈពេល ០៣(បី) ខែ។

**ប្រការពីរ.-**

លេខអត្តសញ្ញាណវិនិយោគិនដែលវិនិយោគិនទទួលបានមុនប្រកាសនេះចូលជាធរមាន ដោយអនុលោមតាមប្រកាសលេខ ០០១/១២ គ.ម.ក/ប្រ.ក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការកំណត់កម្រៃសេវាសម្រាប់ការផ្តល់លេខអត្តសញ្ញាណវិនិយោគិក្នុងវិស័យមូលបត្រ ត្រូវបានបន្តសុពលភាពរហូតដល់រយៈពេល១០(ដប់) ឆ្នាំ គិតពីកាលបរិច្ឆេទផ្តល់លេខអត្តសញ្ញាណវិនិយោគិន ដោយគណៈកម្មការមូលបត្រកម្ពុជា។

**ប្រការ៦.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋាន និងអង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ៧៥៨

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៤

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ